ការសម្ភាសរបស់លោកប៉ា ជុង សីហា

កៈ អ្នកសម្ភាសន៍ ជុង សីហា ខៈ អ្នកត្រូវគេសម្ភាសន៍ឈ្មោះ ជុង ហេង

កៈ ចឹងប៉ាកូនសូមអរគុណសម្រាប់ថ្ងៃនេះ ដែលប៉ាផ្តល់ពេលវេលាដើម្បីកូនអាចធ្វើការសម្ភាសមួយនេះហើយ កិច្ចការមួយនេះវាពិតជាល្អមែនទែនសម្រាប់គ្រួសារ និងប្រទានពរសម្រាប់ក្រុមគ្រួសារដើម្បីឱ្យកូនចៅប៉ា ជំនាន់ក្រោយដើម្បីមានឱកាសស្តាប់សម្លេង និង ស្គាល់ពីជីប្រវត្តិប៉ាកាន់តែច្បាស់លាស់ជាងហ្នឹងទៀត។ ចឹងសម្រាប់ការសម្ភាសថ្ងៃនេះ ធ្វើឡើងនូវថ្ងៃទី២៣ ត្រូវជាថ្ងៃសុក្រ ខែ៩ ឆ្នាំ២០១៦ ហើយខ្ញុំជាកូនជាអ្នកសម្ភាសឈ្មោះជុង សីហា ចឹងប៉ាអាចជួយប្រាប់ឈ្មោះពេញប៉ាបានទេ។
ខៈ ខ្ញុំឈ្មោះជុង ហេង។
កៈ ប៉ាមានឈ្មោះហៅក្រៅទៀតទេ?
ខៈ ឈ្មោះក្រៅហៅ ពេក។
កៈ ប៉ាតែមួយហ្នឹងទេហ្ន៎?
ខៈ អើ!
កៈ ប៉ាសព្វថ្ងៃអាយុប៉ុន្មានដែរ?
ខៈ ៥២ឆ្នាំ។
កៈ អូខេ! ថ្ងៃខែឆ្នាំកំណើតប៉ាអាចជួយប្រាប់បន្តិចបានទេ?
ខៈ អូ! អត់ចាំទេ។
កៈ ចាំឆ្នាំ?
ខៈ ឆ្នាំ១៩៦៥។
កៈ ឆ្នាំ១៩៦៥ ណោះប៉ាណោះ។
ខៈ អឹម!
កៈ ចឹងប៉ាអាចជួយប្រាប់ពីទីកន្លែងកំណើតរបស់ប៉ាបានទេ?
ខៈ នៅក្រុងភ្នំពេញ សង្កាត់លេខ៣។
កៈ ចឹងសម្រាប់ប៉ាមានបងប្អូនប៉ុន្មាននាក់ដែរ?
ខៈ មានបងប្អូន៦នាក់។
កៈ ប៉ាជួយរាប់រៀបឈ្មោះពួកគាត់ម្នាក់ៗ ហើយនិង ភេទប្រុសស្រីចឹងណា?
ខៈ ជុង អេង ភេទស្រី ប៉ាជុងហេង មួយទៀតអី គឹមមួយ មួយទៀតគឹមលី មួយទៀតអាម៉េង មួយទៀតអាមាន។
កៈ បាទ!
ខៈ អឺ! ៦នាក់ ប្រុស៣ ស្រី៣
កៈ ចឹងសម្រាប់បងប្អូនប៉ាបង្កើត សព្វថ្ងៃពួកគាត់នៅស្រុកខ្មែរយើងទាំងអស់ឬក៏មាននៅក្រៅប្រទេសខ្លះ?
ខៈ នៅស្រុកខ្មែរ៤ នៅស្រុកក្រៅ២។
កៈ នៅស្រុកក្រៅ២ មានឈ្មោះអីគេ?
ខៈ អាមួយ និង អាម៉េង។
កៈ ពួកគាត់នៅស្រុកណាដែរ?
ខៈ មិនដឹងរដ្ឋណាទេ ប៉ាភ្លេចហើយ ដឹងតែនៅអាមេរិចទាំង២នាក់
កៈ ចឹងសម្រាប់ប៉ាជាកូនទីប៉ុន្មាន?
ខៈ ទី២!
កៈ ជាកូនទី២។
ខៈ អើ!
កៈ ប៉ាអាចជួយប្រាប់ទាក់ទងនឹងឪពុកម្តាយប៉ាមានឈ្មោះអីដែរ?
ខៈ ឪពុកឈ្មោះជុងពុន ម្តាយឈ្មោះអ៊ូ ញឹម។

ក៖ ២នាក់គាត់ជាខ្មែរសុទ្ធ ឬក៏មានកាត់?
ខ៖ អត់ទេ! ប៉ាកាត់ចិន។
ក៖ ចុះខាងម្តាយប៉ា?
ខ៖ ម្តាយខ្មែរ
ក៖ ២នាក់គាត់មានស្រុកកំណើតនៅណាដែរប៉ា?
ខ៖ កំពង់ឆ្នាំងទាំងអស់។
ក៖ បើសិនជាគិតសព្វថ្ងៃ ពួកគាត់មានអាយុប៉ុន្មាន?
ខ៖ អូ! ច្រើនណាស់ បើកុង ជុងពុន ប្រហែល៨០ជាង
បើម៉ាឯងប្រហែលចូល៧០ជាង។
ក៖ ចឹង ២នាក់គាត់នៅរស់ឬក៏ស្លាប់?
ខ៖ ស្លាប់ហើយ ស្លាប់ទាំង២។
ក៖ សម្រាប់ប្រវត្តិរបស់ប៉ាវិញ តើប៉ាមានកូនប៉ុន្មាននាក់ដែរ?
ខ៖ ប៉ាមានកូន៤នាក់
ក៖ តើប៉ាអាចជួយប្រាប់ឈ្មោះពួកគាត់ម្នាក់ៗ ហើយនិង ភេទបានទេ?
ខ៖ ជុងសម្បត្តិ ជុងលីនណា ជុងលីនដា ហើយជុងសីហា។
ក៖ ពួកគាត់រស់នៅជាមួយនឹងប៉ាសព្វថ្ងៃឬ រស់នៅបែកគ្នាដែរ?
ខ៖ រស់នៅផ្សេងគ្នា។
ក៖ ចឹងសម្រាប់អ៊ីបន្ទាប់
កូនចង់ដឹងទាក់ទងនឹងប្រវត្តិអាពាហ៍ពិពាហ៍របស់ប៉ាវិញ
ប៉ាអាចជួយប្រាប់បានទាក់ទងនឹងប្រវត្តិដែលប៉ាបានជួបម៉ាក់?
ខ៖ អូយ! យូរហើយប៉ាភ្លេចហើយ។
ក៖ អូ! មួយទៀត ប្រពន្ធប៉ាមានឈ្មោះអ្វីដែរ?
ខ៖ ឈ្មោះកែវ ណារុន។
ក៖ បើសិនជាគិតដល់សព្វថ្ងៃ គាត់មានអាយុប៉ុន្មានដែរ?
ខ៖ បើដល់ឥឡូវប្រហែលជា ៤៩ឬ៥០អីហ្នឹង។
ក៖ ចឹងប៉ាអត់ចាំប្រវត្តិដែលប៉ាធ្លាប់ជួបគាត់អីទេ?
ខ៖ អូ! អត់ចាំទេ។
ក៖ អត់ចាំឆ្នាំ?
ខ៖ អេ៎ឆ្នាំ ដូចឆ្នាំ៨៥។
ក៖ កាលប៉ាជួបគាត់មុនដំបូង ប៉ាជួបនៅណាដែរ?
ខ៖ ភ្នំពេញយើង។
ក៖ ប៉ុន្តែស្រុកកំណើតគាត់នៅណាដែរប៉ា?
ខ៖ ស្រុកកំណើតនៅស្វាយរៀង។
ក៖ ចឹងសម្រាប់ការរៀបអាពាហ៍ពិពាហ៍ប៉ា
គឺទទួលដឹងសងខាងពីឪពុកម្តាយទាំងសងខាង ពួកគាត់ទទួលស្គាល់?
ខ៖ អត់មានឪពុកម្តាយទេ ខាងស្រីមានតែបងប្អូន។
ក៖ ចឹងបងប្អូនគាត់ទទួលស្គាល់ថាបានរៀបការអីចឹងទៅ។
ខ៖ អឺមៗ!
ក៖ ចឹងសម្រាប់ការរៀបអាពាហ៍ពិពាហ៍ សម្រាប់ចំណងដៃវិញ
តើមានបណ្ណាការទេ?
ខ៖ មានតើ!
ក៖ បណ្ណាការជំនាន់ហ្នឹង ប៉ាបង្គាប់ជាអ្វីដែរ?
ខ៖ ឱ្យលុយ ជាលុយ។
ក៖ លុយជាប៉ុន្មានដែរប៉ា?
ខ៖ ភ្លេចហើយ ប៉ាភ្លេចមិនដឹងជាលុយកាលជំនាន់ហ្នឹងមិនប៉ុន្មានអីប៉ុន្មានទេ។
មានក្រដាស៥០ មានក្រដាសអីណា កាលជំនាន់ហ្នឹង ៨០ជាងចឹងហើយ។
ក៖ ចឹងសម្រាប់ប៉ា បើសិនជាគិតតាមឆ្នាំសុរិយគតិប៉ាកើតក្នុងឆ្នាំសត្វណាដែរ?

ខៈ សត្វពស់ ម្យាញ់។
កៈ សម្រាប់កុមារីភាពប៉ាពីតូចមក ប៉ាធ្លាប់រៀនចប់ត្រឹមថ្នាក់ទីប៉ុន្មានដែរ?
ខៈ ប៉ារៀនត្រឹមទី១០ សម័យលន់ នល់។
កៈ សម័យលន់នល់ បើយើងគិតមកដល់សព្វថ្ងៃ ថ្នាក់ទី១០ស្មើនឹងថ្នាក់ទី?
ខៈ ថ្នាក់ទី៣ ទី៤យើងហ្នឹង។
កៈ ចឹងជំនាន់ថ្នាក់ទី៣ ទី៤ប៉ាចេះសរសេរ ចេះអានខ្លះ?
ខៈ អឺម! ថីមិនចេះសរសេរ ចេះអាន។
កៈ សម្រាប់សាលារៀន ប៉ាអាចចាំឈ្មោះបានអីទេ?
ខៈ អើ! សាលាបាក់ទូក។
កៈ អូ! សាលាបាក់ទូនដូចផាបងស្រីដែរ។
ខៈ អឺម!
កៈ ចឹងរៀនសាលាបាក់ទូកដូចគ្នា។
ខៈ អឺម!
កៈ ចឹងប៉ាចេះភាសាអ្វីខ្លះ?
ខៈ មានចេះអីទេ ចេះតែចិន(កាច្ចរ) តិចតួច។
កៈ ចិន(កាច្ចរ) វៀតណាម?
ខៈ វៀតណាម បកបាន បកអត់បានប៉ុន្មានទេ?
កៈ បកបាន តែអាចនិយាយបាន។
ខៈ អើ! អាចនិយាយបាន ជ្រៅពេកនិយាយអត់បានទេ។
កៈ ចឹងភាគច្រើនភាសាវៀតណាមហ្នឹង ចិន(កាច្ចរ) ប្រើផាលក្ខណៈមិចវិញ?
ខៈ ធម្មតាៗ!
កៈ ធម្មតាៗ!
ខៈ និយាយមួយៗ។
កៈ និយាយជាមួយបងប្អូន និង ក្រុមគ្រួសារ។
ខៈ អឺម!
កៈ ហើយអើ ហើយសសម្រាប់(សើច)
ប៉ាមានធ្លាប់រស់នៅឆ្លងកាត់ជំនាន់ប៉ុលពតដែរទេ?
ខៈ ធ្លាប់!
កៈ ប៉ាអាចជួយប្រាប់រយៈពេល?
ខៈ អូ! អត់ចាំទេ អត់ចាំទេ អាហ្នឹងណោះ។
កៈ អឺម!
ខៈ ឆ្នាំ៧៥ចេញទៅនៅណាដូចនៅកំពង់កង់ ផ្លូវទៅស្អាងកោះធំហ្នឹង
ដល់ហើយគេជម្លាសទៅវៀតណាមឆ្លងកាត់វៀតណាមបាន បកមកវិញឆ្នាំ៧៩
ប៉ុណ្ណឹងរស់នៅដីខ្មែររហូតអស់ហើយ។
កៈ ចឹងសម្រាប់ប្រវត្តិទាក់ទងការធ្វើ ការងារតាំងពីតូចណ៎ា។
ខៈ តូចនៅរៀនតើ មានធ្វើអី។
កៈ ប៉ាធ្លាប់ធ្វើអីគេខ្លះក្នុងគ្រួសារ?
ខៈ អូ! កាលហ្នឹងជួយម៉ា គាត់ដេរខោអាវអីហ្នឹង។ កាលហ្នឹង
ជួយកុងជួយដេរខោអាវដេរអីឱ្យគាត់ហើយក្រោយមកទៅរកស៊ី។
កៈ រកស៊ីអីទៅប៉ា?
ខៈ រកស៊ីគ្រឿង តិចតួចឆ្លងសមុទ្រហ្នឹងណា តែប៉ុណ្ណឹង។ រកស៊ីយូរ
អស់ដើមហើយ(សើច)។
កៈ ចឹងថាប៉ាធ្លាប់រកស៊ីតែម្ដង។
ខៈ អឺម! អស់ដើម។
កៈ ចឹងបន្ទាប់ពីជំនាន់ប៉ុលពតបែកមក ប៉ាបានធ្វើអីគេទៀត?
ខៈ ទៅរៀន!
កៈ ទៅរៀន នៅសាលាណាបន្ត?

ខៈ អេ! រៀននៅបឹងត្របែក អើ! សាលាបណ្ណះវិជ្ជាហើយ
ទើបបានដូរទៅបឹងត្របែក។
កៈ រៀនដល់ថ្នាក់ណាដែរប៉ា?
ខៈ ដូចទី៧ ទី៨ហើយឈប់គេចាប់យកធ្វើទាហាន។
កៈ ចឹងប៉ាធ្លាប់ធ្វើទាហានដែរជំនាន់ហ្នឹង?
ខៈ អូ! អត់ធ្លាប់ជំនាន់ហ្នឹង រត់ចង់តែងាប់ហើយ(សើច)។
កៈ ម៉េចបានជាគេចាប់ធ្វើទាហានចឹង?
ខៈ យេ! សម័យកុម្មុនីសគេចាប់ហើយ។
កៈ បែកពីប៉ុលពតដែរហ្នឹង។
ខៈ អឺម! ហ្នឹងគេចាប់ធ្វើទាហានដើម្បីវាយខ្មែរក្រហម វាយអី។
កៈ អូ! ចឹងថា ទោះបែកប៉ុលពត ក៏នៅសល់ខ្មែរក្រហមខ្លះ។
ខៈ អឺម!
កៈ នៅចង់ធ្វើបដិវត្តប្រឆាំង។
ខៈ អឺម!
កៈ ចឹងសម្រាប់ម្ហូបប៉ាចូលចិត្តម្ហូបអ្វីជាងគេ?
ខៈ ឆាខ្ញី(សើច)។
កៈ ឆាខ្ញី វាមានច្រើនប្រភេទ(សើច) អ្នកខ្លះចូលចិត្តមាន់ជ្រូក។
ខៈ ត្រី ជ្រូកដូចតែគ្នាហ្នឹង ហូបបានដូចតែគ្នាហ្នឹងឱ្យតែឆាខ្ញី។
កៈ ឱ្យតែឆាខ្ញី អត់ចូលចិត្តអ្វីផ្សេងទៀតទេណោះ។
ខៈ អត់ទេ!
កៈ ចឹងភេសជ្ជៈ ប៉ាចូលចិត្តផឹកទឹកអ្វី?
ខៈ អឺម! មិនដែល អឺកាហ្វេហ្នឹង។
កៈ ហើយចូលចិត្តជក់បារីជាងគេ។
ខៈ អឺម! (សើច)
កៈ អឺម! ទៀត(សើច) អូខេ! ចឹងសម្រាប់ចម្រៀង ប៉ាចូលចិត្តស្តាប់ចម្រៀងណា។
ខៈ ចប់ហើយរឿងចម្រៀង មិនដែលស្តាប់ទេ។
កៈ ប៉ាអត់ចេះច្រៀងទេណោះ។
ខៈ អឺម!
កៈ អត់ចេះរាំ?
ខៈ អត់ចេះទេ។
កៈ សម្រាប់ទាក់ទងនឹងប៉ាជួយបកស្រាយរឿង ឬក៏និយាយទាក់ទងនឹងភាព
ចង់ឱ្យប៉ាឯងគិតទាក់ទងហ្នឹងដែរ ដោយសារកូនចង់ប៉ាជួយចែកចាយពី
ឆាកជីវិតពីតូចដល់ធំណាមកដល់សព្វថ្ងៃ តើប៉ាឯងគិតថា
ពេលវេលាណាដែលធ្វើឱ្យប៉ាពិបាកចិត្តជាងគេ
ហើយជួបបញ្ហាច្រើនជាងគេដែលធ្វើឱ្យប៉ា។
ខៈ ពេលវេលាដែលពិបាកចិត្តជាងគេ គឺរឿងអត់លុយហ្នឹង
មានក្រៅពីរកលុយបានអីមិនបានហ្នឹងទេ។ បើអត់លុយមានតែរកអីឥឡូវនេះ
រត់ម៉ូតូឌុបស្មានតែរស់អីរាល់ថ្ងៃរកមិនចង់គ្រប់ផង រត់ម៉ូតូឌុបឥឡូវ
រកអីទៀតឥឡូវហ្នឹង។
កៈ ចឹងនៅពេលប៉ាជួបឧបសគ្គចឹងៗ ភាគច្រើនប៉ាប្រើវិធិសាស្ត្រ
របៀបណាដោះស្រាយ?
ខៈ អឺម! ដឹងហើយ រត់ម៉ូតូឌុបចិញ្ចឹមពួកឯងដល់ត្រឹមណា ដល់ត្រឹមណាដឹងហើយ
ពួកឯងដឹងហើយ(សើច) រកតាំងពីម៉ែឯងស្លាប់
រត់ម៉ូតូឌុបរហូតដល់ថ្នាក់ទីប៉ុន្មាន គឺពួកឯងដឹងទាំងអស់គ្នាហើយ
ហើយលួមជួលផ្ទះគេនៅទៀត។ មួយខែៗហ្នឹងអស់ប៉ុន្មាន សាហុយចាយ
សាហុយជួលផ្ទះ ដល់ពួកឯងរាងធំតិចអស់សាហុយហ្នឹងប៉ុន្មានទៀត
តែប៉ុណ្ណឹងហើយគិតមើលទៅកូនទាំង៤នាក់ហ្នឹង។

ក៖ ប្រពន្ធប៉ាគាត់ ប្រហែលជាស្លាប់ប៉ុន្មានឆ្នាំហើយ?
ខ៖ ស្លាប់ឆ្នាំ២០០១ដល់ឥឡូវ។
ក៖ ១៥ឆ្នាំ!
ខ៖ ១៦ អើ១៥ឆ្នាំហើយ។
ក៖ ចឹងចាប់ពីពេលនោះមក ប៉ាជាអ្នកទទួលរ៉ាប់រងចិញ្ចឹម កូនបីបាច់ទាំងអស់?
ខ៖ អើ!
ក៖ ចឹងសម្រាប់ការនៅចិញ្ចឹម កូនសព្វថ្ងៃ ពីមុន១៥ឆ្នាំ
ក្នុងកំឡុងពេល១៥ឆ្នាំអត់មានអ្នកណា ជួយទំនុកបម្រុងថែម
មានអ្នកផ្សេងដើម្បីជួយ?
ខ៖ មាន! អ៊ីមួយឯងជួយបានតិចតួច ហើយក្រៅពីហ្នឹងប៉ារកទាំងអស់។
ក៖ អូខេ!
ខ៖ បើអត់រកបានអីរស់ កូនអើយកូន។ រត់តាំងពីម៉ូតូថ្មីដល់ម៉ូតូចាស់អីហ្នឹង
ជុះតាមផ្លូវអីហ្នឹង។
ក៖ ចង់សួរមួយវិញទៀត តើភាពលំបាកដែលប៉ាគិតថា
ធ្វើជាឪពុកទោលត្រូវចិញ្ចឹមកូនដល់ទៅ៤នាក់ តើវាលំបាកកម្រិតណា
ប៉ាជួយបកស្រាយ?
ខ៖ អូ! អារឿងលំបាកហ្នឹង រកអីប្រៀបមិនបានទេ វាថាគិតអស់ហើយ
គិតឡើងក្បាលចង់ឡើងរលេស ហើយ
លួមបានពួកឯងធំមួយៗហ្នឹងទៅរៀនសូត្រលួមមួយចប់។ ឥឡូវគិតមើល
ឯងរៀនថ្នាក់ទី១រហូតដល់រៀនថ្នាក់ទីប៉ុន្មាន អាហ្នឹងប៉ុន្មានឆ្នាំ
គឺពួកកូនឯងយល់ហើយ។ អត់មានអ្នកណានេះទេ ហើយប៉ានៅតែខំរកចឹង
មិនដែលដើរលេង ស៊ីផឹកដូចគេអត់ចេះសោះ។ អើ! បើថាបារីកាហ្វេហ្នឹងមានមែន
បើឱ្យដើរស៊ីផឹកដូចគេអត់មានទេ មានលុយណារត់ម៉ូតូឌុប មួយថ្ងៃរក
ចិញ្ចឹមកូនមិនរស់ផង មានលុយណាទៅផឹក បានហើយកូន។ អស់ហើយ
និយាយៗអញចង់តែស្រក់ទឹកភ្នែក នាំតែពិបាកចិត្តទេ។
ក៖ កូនចង់ឱ្យប៉ាជួយចែកចាយទៀត ដោយសារតែអា
សម្លេងហ្នឹងវាមានផលប្រយោជន៍ច្រើនសម្រាប់កូនចៅប៉ា។
ចឹងកូនចង់ឱ្យប៉ាជួយឆ្លើយ នូវអ្វីទាំងអស់ដែលជាបទពិសោធន៍ជិវិត
វាជាប្រយោជន៍ដល់កូនចៅប៉ាជំនាន់ក្រោយទៀត។
ខ៖ អឹម! មានអីទៀតហ្នឹង ឆាកជិវិតមានតែប៉ុណ្ណឹង មនុស្សយើងកើតមកតែ
ងខ្លះមានលំបាក ហើយខ្លះស្រួល ហើយខ្លះគេស្រណុកដេកស៊ីទៅ។
យើងកើតមកក្នុងឆាកជិវិតនេះ យើងទ្រាំតិចទៅក្នុងការរស់នៅ
ក្នុងឆាកជិវិតមិនមែនម្នាក់ឯងទេ ដោយមានកូន៤-៥នាក់ទៀត។
ក៖ សម្រាប់ពេលវេលាដែលប៉ាគិតថាសប្បាយចិត្តជាងគេ គឺនៅពេលណា?
ខ៖ គ្មានរកផ្លូវណាសប្បាយទេ រកសប្បាយអត់ឃើញទេ
មានស្អីបានសប្បាយឥឡូវហ្នឹង សប្បាយចិត្តដែលថាកូនវាមានការងារខ្លះៗហើយ
និង ធូរម្យ៉ាងទៅស្រួលទៅ វាដូចមុនហ្នឹង ក៏ត្រូវរ៉ាប់រងទាំង អស់។
ក៖ រ៉ាប់រងច្រើន។
ខ៖ ហ្នឹងហើយ មិនមែនតិចទេ។ ឥឡូវកូនបានការងារធ្វើហើយក៏ប៉ាធូរដែរ
អត់មានធ្វើអីដែលពិបាកទេ។ ពិបាកតែរឿងរកលុយ ស៊ីចាយអីហ្នឹង
គឺវាយ៉ាប់ណាស់ ពីព្រោះអ្នករត់ម៉ូតូឌុបឥឡូវមានច្រើន
ក្នុងមួយថ្ងៃអត់បាន២០,០០០ ទេឥឡូវនេះ បានហើយកូន។
ក៖ ចឹងអរគុណសម្រាប់ថ្ងៃនេះប៉ាបានផ្តល់ឱកាសឱ្យកូនសម្ភាសជាសណួរ
ចុងក្រោយកូនចង់សួរថា តើប៉ាយល់ព្រមឱ្យកូនដាក់សម្លេងដែលកូនសម្ភាស
នៅក្នុងវេបសាយសាលា**BYU** ដែរឬទេ?
ខ៖ បាទ ព្រម!

កះ ចឹង អរគុណប៉ា ជូនពរឱ្យប៉ាមានសុខភាពល្អ
ហើយចៀសផុតពីជម្ងឺផ្សេងៗទៀត។